**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃអង្គារ ១៤ រោច ខែ អាសាឍ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣*

*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៩*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មានស្តីពី ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាមួយនិង លោកជំទាវ Maria Sargren ឯកអគ្គរាជទូតស៊ុយអែត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៩, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារជាមួយលោកជំទាវ **Maria Sargren** ឯកអគ្គរាជទូតស៊ុយអែត ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្នុងខណៈដែលលោកជំទាវត្រូវបញ្ចប់បេសកកម្មការទូតនៅកម្ពុជា ក៏ដូចជា ពិភាក្សាលើការបន្តពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការទ្វេភាគី **កម្ពុជា-ស៊ុយអែត** ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងវាយតម្លៃខ្ពស់ចំពោះប្រជាជន និងរាជរដ្ឋាភិបាលស៊ុយអែត ដែលប្រទេសស៊ុយអែតគឺជាដៃគូដ៏សំខាន់ចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា នាពេលកន្លងមក ។ សមិទ្ធិផលដែលកម្ពុជាទទួលបាន គឺមិនអាចកាត់ផ្តាច់ពីការគាំទ្ររបស់រដ្ឋាភិបាលស៊ុយអែត ក៏ដូច លោកជំទាវឯកអគ្គរាជទូតផ្ទាល់ ក្នុងអាណត្តិការងារការទូតរបស់លោកជំទាវនៅកម្ពុជា ។ ជាក់ស្តែង, ស៊ុយអែតបានចូលរួមចំណែកយ៉ាងសកម្មក្នុងកម្មវិធីកែទម្រង់ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងតែអនុវត្តន៍ តាមរយៈការផ្តល់កិច្ចគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ ក៏ដូចជា បច្ចេកទេស ជាអាទិ៍ ដល់កម្មវិធីការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ចាប់តាំងពីដំណាក់កាលទី ១ មក ពិសេស ការងារកែទម្រង់វិស័យពន្ធដារ ជាដើម ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានថ្លែងអំណរគុណដល់ភាគីមិត្តចំពោះការផ្តល់ជាជំនួយបច្ចេកទេស ក៏ដូចជា ការចែករំលែកបទពិសោធន៍ការងារចំពោះវិស័យពន្ធដារតាមរយៈការផ្តល់ទស្សនៈកិច្ចសិក្សាទៅកាន់ប្រទេសស៊ុយអែតផ្ទាល់ ជាដើម ។

លោកជំទាវ **Maria Sargren** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការផ្តល់កិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរពីស្ថាប័នពាក់ព័ន្ធរបស់កម្ពុជា ក្នុងរយៈពេល ០៣ ឆ្នាំ ដែលលោកជំទាវបានមកបំពេញបេសកកម្មការទូតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានជំរុញឱ្យបេសកកម្មការទូតរបស់លោកជំទាវទទួលបានជោគជ័យដ៏ត្រចះត្រចង់មកដល់ថ្ងៃនេះ ។ លោកជំទាវផ្ទាល់ ជាសាក្សីនៃការរីកចម្រើនឥតឈប់ឈររបស់កម្ពុជានាពេល

បច្ចុប្បន្ន ជាមួយកំណើនសេដ្ឋកិច្ចរឹងមាំ ដែលការសម្រេចបានទាំងនេះ គឺកើតមកពីការខិតខំប្រឹងប្រែងរបស់រាជ-រដ្ឋាភិបាលកម្ពុជា ជាពិសេស ការដាក់ចេញ និងការអនុវត្តកិច្ចការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ ។

កិច្ចពិភាក្សា ក៏បានផ្តោតលើការកែទម្រង់ឱ្យកាន់តែស៊ីជម្រៅបន្ថែមទៀតលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសារធារណៈ នៅពេលដែលកម្មវិធីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (FMIS) ត្រូវបានដាក់ឱ្យអនុវត្តន៍ និងពង្រីកទៅតាមក្រសួង-ស្ថាប័នផ្សេងៗ, តម្លាភាព និងគណនេយ្យភាព, និងការរៀបចំបង្កើតជាមជ្ឈមណ្ឌលគ្រប់គ្រប់ទិន្នន័យ និងស្ថិតិ (Data Center) រួមមួយ ជាដើម ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ក៏បានជូនពរ លោកជំទាវ Maria Sargren ឱ្យទទួលបានជោគជ័យក្នុងតួនាទីថ្មីរបស់លោកជំទាវនាពេលខាងមុខ និងបានគូសបញ្ជាក់ថា កម្ពុជា នឹងបន្តខិតខំលើកកម្ពស់កិច្ចសហប្រតិបត្តិការ និងមិត្តភាពឱ្យកាន់តែស្និតរម្មួតបន្ថែមទៀត ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ប្រទេស និងប្រជាជននៃប្រទេសទាំងពីរ កម្ពុជា-ស៊ុយអែត ។